**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី**

**ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព (ផ.ក.អ.)**

**លេខាធិការដ្ឋាន**

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# ដំណើរការចាប់ឆ្នោតជុំទី១សម្រាប់អ្នកបានដាក់ពាក្យស្នើសុំដី នៃកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព

“**កម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព**” ត្រូវបានផ្តួចផ្តើមឡើងដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងគោលបំណងបង្កើនការការពារ និងអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាពសម្រាប់កូនចៅជំនាន់ផង និងបង្កើនប្រសិទ្ធភាព ផលិតភាពនៃការប្រើប្រាស់ដីរដ្ឋផង តាមរយៈការផ្តល់ដីក្រោមទម្រង់សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីសម្រាប់សង់លំនៅឋានប្រកបដោយសមធម៌ និងគាំទ្រគម្រោងអភិវឌ្ឍសហគមន៍ ព្រមទាំងការពារព្រៃនៅជិតទីតាំងផ្តល់ដីប្រកបដោយចីរភាព។ **កម្មវិធីនេះ រួមគ្នាគិត រួមគ្នាធ្វើ រួមគ្នាទទួលខុសត្រូវ និងរួមគ្នាទទួលផល ព្រមទាំងដោះស្រាយការទន្ទ្រានដីរដ្ឋដោយខុសច្បាប់។** គណៈកម្មាធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព (ផ.ក.អ.)ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/១១២៤/១៤១២ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ដែលមាន**សម្តេចធិបតី នាយករដ្ឋមន្ត្រី**ជាប្រធាន។ បន្ទាប់ពីបានបណ្តុះបណ្តាលដល់មន្ត្រីឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តឱ្យបានយល់ច្បាស់ពីនីតិវិធីការងារពិសេសពីលក្ខណៈសម្បត្តិទាំង៤ រួមមាន គ្រួសារដែលមានសញ្ជាតិខ្មែរពីកំណើត គ្មានដី ក្រីក្រពិតប្រាកដ និងចង់ទៅរស់នៅទីតាំងអនុវត្តកម្មវិធី របស់អ្នកមានបំណងដាក់ពាក្យស្នើសុំដីរួចមក លេខាធិការដ្ឋាន ផ.ក.អ. បានផ្សព្វផ្សាយយ៉ាងទូលំទូលាយពីលក្ខណៈសម្បត្តិទាំង៤ដល់ប្រជាពលរដ្ឋហើយប្រជាពលរដ្ឋដែលមានលក្ខណៈវិនិច្ឆ័យស្របតាមលក្ខណៈសម្បត្តិទាំង៤ខាងលើ បានមកធ្វើស្វ័យប្រកាសនិងដាក់ពាក្យស្នើសុំដីចាប់ពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ នៅឃុំ / សង្កាត់ចំនួន ១ ១៨២ឃុំ/ សង្កាត់ ដោយអ្នកបានដាក់ពាក្យស្នើសុំដីមានចំនួនសរុប ១២ ៣២៩គ្រួសារ និង៤៧០ឃុំ/ សង្កាត់ពុំមានអ្នកដាក់ពាក្យស្នើសុំដីឡើយ ក្នុងចំណោម ១ ៦៥២ឃុំ/ សង្កាត់ ទូទាំងប្រទេស។

ដោយមានការយកចិត្តទុកដាក់ ណែនាំ និងតម្រង់ទិសជាប្រចាំពី**សម្តេចធិបតី នាយករដ្ឋមន្ត្រីនិងជាប្រធាន ផ.ក.អ.** លេខាធិការដ្ឋានបានកំណត់ទីតាំងដីនៅភូមិសាស្ត្រ អូរសែរ ឃុំស្តៅនិងឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង ហើយបានរៀបចំផែនការប្រើប្រាស់ដី ផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផែនការបែងចែកដីឡូតិ៍លម្អិត និងផែនការអភិវឌ្ឍដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនដែលគ្រោងនឹងទៅរស់នៅទីតាំងនោះ។ ពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លេខាធិការដ្ឋាន ផ.ក.អ. បាននិងកំពុងរៀបចំផ្លូវមេ និងផ្លូវរង ព្រមទាំងក្បាលដីឡូតិ៍នីមួយៗ។ ទន្ទឹមនឹងនេះ ដើម្បីអនុវត្តជំហានបន្ទាប់ ក្នុងការជ្រើសរើសបុគ្គលមានលក្ខណៈសម្បត្តិ

គ្រប់គ្រាន់អាចមានសិទ្ធិទទួលដីនោះ **លេខាធិការដ្ឋានគ្រោងនឹងធ្វើការចាប់ឆ្នោតជុំទី១**សម្រាប់អ្នកបានដាក់ពាក្យសុំដីនៃកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីប្រមូលផ្តុំអភិវឌ្ឍដោយចីរភាព ចាប់ពីថ្ងៃទី ៣០ ខែមិថុនា ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥។ ការចាប់ឆ្នោតជ្រើសរើសនេះគឺធ្វើឡើងម្តងមួយខេត្តៗ និងធ្វើឡើងដោយតម្លាភាព សុក្រឹតភាព យុត្តិធម៌ និងអាចជឿទុកចិត្តបាន ដោយបង្ហាញឈ្មោះគ្រួសារដែលបានដាក់ពាក្យទាំងអស់ ទៅក្នុងប្រអប់ចាប់ឆ្នោតដែលអាចមើលធ្លុះបាន។ មុននឹងធ្វើការចាប់ឆ្នោតត្រូវបង្វិលធុងឆ្នោតដើម្បីច្របល់សន្លឹកឆ្នោតឱ្យបានសព្វល្អ ទើបអ្នកចាប់ឆ្នោតត្រូវចាប់យកសន្លឹកឆ្នោតម្តងមួយសន្លឹកៗហើយបង្ហាញជាសាធារណៈ ដោយប្រកាសឈ្មោះអ្នកដាក់ពាក្យសុំដី រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងលេខបង្កាន់ដៃទទួលពាក្យ។ ក្នុងការចាប់ឆ្នោតជុំទី១នេះ នឹងជ្រើសរើសយកអ្នកមានសំណាងចំនួន ២ ៥០០ គ្រួសារ ដោយកំណត់អត្រាចំនួន ២០% តាមរាជធានី ខេត្ត ដូចនេះចំនួនសន្លឹកឆ្នោតអ្នកបានដាក់ពាក្យស្នើសុំដីដែលត្រូវចាប់យកតាមរាជធានី ខេត្តនីមួយៗ មានចំនួនខុសៗគ្នា អាស្រ័យដោយចំនួនអ្នកបានដាក់ពាក្យស្នើសុំដីតាមរាជធានី ខេត្ត។ ការចាប់ឆ្នោតនេះ ត្រូវធ្វើរហូតដល់គ្រប់ចំនួនកំណត់ខាងលើ។

ចំពោះគ្រួសារដែលនឹងមានសំណាងក្នុងការចាប់ឆ្នោតចំនួន ២ ៥០០គ្រួសារ តាមលំដាប់លេខរៀងដែលចាប់ឆ្នោតបានក្នុងរាជធានី ខេត្តសាមី ក្នុងនោះ÷

ក.អ្នកបានដាក់ពាក្យស្នើសុំដី ចំនួន ៥០០គ្រួសារ ដែលមានសំណាងលំដាប់លេខរៀងតាមការចាប់ឆ្នោតបានមុនគេនិងបន្តបន្ទាប់(៤%)ក្នុងរាជធានី/ខេត្តសាមី ត្រូវបានចុះត្រួតពិនិត្យបុគ្គលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលអាចមានសិទ្ធិទទួលដីសម្រាប់គម្រោងទី១ នៅភូមិសាស្ត្រ អូរសែរ ឃុំស្ដៅនិងឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង។

ខ.ក្នុងចំណោមអ្នកដាក់ពាក្យស្នើសុំដី ដែលមានសំណាង ចំនួន ២ ០០០គ្រួសារ ដែលនៅសល់ពុំទាន់បានចុះទៅត្រួតពិនិត្យលក្ខណៈសម្បត្តិនឹងត្រូវចុះត្រួតពិនិត្យបន្តបន្ទាប់ សម្រាប់ជំនួសបំពេញចំនួនកំណត់ ៥០០គ្រួសារ និង/ឬគម្រោងបន្ទាប់ តាមលំដាប់លេខរៀងបន្តបន្ទាប់ តាមលទ្ធផលនៃការចាប់ឆ្នោតក្នុង រាជធានី ខេត្តសាមី។

ក្រោយពេលចាប់ឆ្នោតនេះរួច ក្រុមការងារចម្រុះចុះត្រួតពិនិត្យបុគ្គលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលដីរបស់លេខាធិការដ្ឋាន ផ.ក.អ. នឹងទំនាក់ទំនងជាមួយរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ដើម្បីចុះពិនិត្យភាពសមស្របអ្នកចាប់ឆ្នោតបានទាំង៥០០គ្រួសារ ដែលមានសំណាងលំដាប់លេខរៀងតាមការចាប់ឆ្នោតបានមុនគេនិងបន្តបន្ទាប់(៤%)ក្នុងរាជធានី ខេត្តសាមី។ ក្នុងករណីពេលចុះពិនិត្យឃើញថា មានអ្នកដាក់ពាក្យស្នើសុំដីមួយចំនួនមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអាចទទួលដីបាន អ្នកដាក់ពាក្យនោះនឹងពុំជាប់ឈ្មោះក្នុងកម្មវិធីនេះទេ ហើយក្រុមការងារចម្រុះនឹងជ្រើសរើសជំនួសបំពេញចំនួនកំណត់ឱ្យគ្រប់ចំនួន ៥០០ គ្រួសារ តាមលំដាប់លេខរៀងបន្តបន្ទាប់តាមលទ្ធផលនៃការចាប់ឆ្នោតក្នុង រាជធានី/ខេត្តសាមី។

ដោយឡែកសម្រាប់អ្នកបានដាក់ពាក្យស្នើសុំដីដែលនៅសល់ចំនួន **៩ ៨២៩គ្រួសារ** ដែលពុំទាន់មានសំណាងជាប់ឈ្មោះក្នុងលទ្ធផលនៃការចាប់ឆ្នោតជុំទី១នឹងត្រូវចាប់ឆ្នោតនៅជុំបន្តបន្ទាប់ទៀត។

**ក្នុងន័យនេះ លេខាធិការដ្ឋានមានកិត្តិយស សូមជម្រាបជូនសាធារណជន ជាពិសេសអ្នកដែលបានដាក់ពាក្យស្នើសុំដីតាមឃុំ សង្កាត់ទូទាំងប្រទេស ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៥ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ កន្លងមក ហើយបានទទួលបង្កាន់ដៃទទួលពាក្យស្នើសុំដី សូមបងប្អូនចូលរួមទស្សនា តាមដាន និងផ្ទៀងផ្ទាត់ឈ្មោះ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងលេខបង្កាន់ដៃទទួលពាក្យស្នើសុំដីរបស់ខ្លួន។**

ដំណើរការនៃការចាប់ឆ្នោតជុំទី១នេះ នឹងប្រព្រឹត្តទៅនៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា(ទទក) តាមកាលបរិច្ឆេទដូចខាងក្រោម ÷

- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ សម្រាប់ខេត្តបាត់ដំបង ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង។
- ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ សម្រាប់ខេត្តកំពង់ចាម ខេត្តរតនគិរី ខេត្តតាកែវ ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ។
- ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ សម្រាប់ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តកំពត និងខេត្តព្រះសីហនុ។
- ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ សម្រាប់ខេត្តក្រចេះ រាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង និងខេត្តប៉ៃលិន។
- ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ សម្រាប់ខេត្តកណ្ដាល ខេត្តពោធិ៍សាត់ ខេត្តមណ្ឌលគិរី ខេត្តកំពង់ឆ្នាំង និងខេត្តកែប។

**ការចាប់ឆ្នោតនេះ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង ១៣ : ០០នាទីរសៀលតទៅ នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា (ទទក) ហើយដែលនឹងធ្វើការផ្សាយផ្ទាល់ពីទូរទស្សន៍ជាតិកម្ពុជា(ទទក) ក៏ដូចជានៅតាមបណ្ដាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត នៅលើទំព័រហ្វេសប៊ុក(Facebook Page)ផ្លូវការរបស់លេខាធិការដ្ឋាន ផ.ក.អ. និងលើទំព័រហ្វេសប៊ុកផ្លូវការរបស់ទូរទស្សន៍ជាតិកម្ពុជា(ទទក) ។**

លេខាធិការដ្ឋានសង្ឃឹមយ៉ាងមុតមាំថា សាធារណជននិងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមចំណែកគាំទ្រ និងអនុវត្តយ៉ាងសកម្មក្នុងកម្មវិធីផ្ដល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មនសិការស្នេហាជាតិ ក្នុងឧត្ដមប្រយោជន៍បម្រើប្រជាពលរដ្ឋនិងប្រទេសជាតិ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកលេខាធិការដ្ឋានតាមរយៈទូរស័ព្ទ Hotline 1255 (ដោយឥតគិតថ្លៃ) នៅរៀងរាល់ម៉ោងធ្វើការ តាមរយៈឆានែលតេឡេក្រាម÷ https://bit.ly/secpka និងផេកហ្វេសប៊ុកផ្លូវការ÷ លេខាធិការដ្ឋាន ផ.ក.អ.។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥